

# ផ្ទះរបស់សុខា

# Sokha's House


Written by TukTuk

Illustrated by Kaho Yamada




TUKTUK

# ១



ជម្រាបសួរ! ខ្ញុំឈ្មោះសុខា។ ខ្ញុំនឹងប្រាប់អ្នកអំពីផ្ទះរបស់ខ្ញុំ!
តើអ្នកឃើញផ្ទះមួយនៅពីក្រោយខ្ញុំទេ? នោះជាផ្ទះរបស់ខ្ញុំ។

໑






នៅផ្ទះរបស់ខ្ញុំមានដើមដូង។ តើមានដើមដូងចំនួនប៉ុន្មាន? ១ ២! មានប២ដើម។
នៅពេលដែលខ្ញុំស្រេកទឹក បងប្រុសច្បងរបស់ខ្ញុំនឹងឡើងទៅបេះដូងឱ្យខ្ញុំផឹក។



# ដ






នៅពីមុខផ្ទះរបស់ខ្ញុំ មានពាងទឹក។ តើមានពាងទឹកចំនួនប៉ុន្មាន? ១ ២ ៣! មាន៣។
ពួកយើងប្រើប្រាស់វា នៅពេលដែលពួកយើងងូតទឹក ចម្អិនអាហារនិងធ្វើអ្វីផ្សេងទៀត។

# ដ






មើលន៎! នៅជុំវិញពាងទឹកមានកូនឆ្កែ។ តើមានកូនឆ្កែចំនួនប៉ុន្មាន?
១ ២ ៣ ៤! មាន៤ក្បាល។ ពួកវាទើបតែកើតកាលពីខែមុនទេ។ តើពួកវាស្អាតដែរទេ?

# ង





មើលទៅនុ៎ះ! មានកូនមាន់ទៀតផង។ តើមានកូនមាន់ចំនួនប៉ុន្មាន?
១ ២ ៣ ៤ ៥! មាន៥ក្បាល។ ចេបៗ ចេបៗ ចេបៗ! តើម៉ែនៅទីណា?
កូនមាន់កំពុងតែរកមេរបស់ពួកវា។





តើអ្នកឃ្លានមែនទេ? កុំបារម្ភអីណា! ពួកយើងមានដើមស្វាយចំនួន១ដើម។
តោះទៅមើលថា តើមានផ្លែស្វាយចំនួនប៉ុន្មានផ្លែដែលយើងអាចញ៉ាំបាន?
តោះរាប់ជាមួយគ្នា ១ ២ ៣ ៤ ៥ ៦! មាន៦ផ្លែ។






ពួកយើងថែមទាំងមានដើមចេកចំនួន១ដើមទៀតផង។
តើមានផ្លែចេកចំនួនប៉ុន្មានផ្លែដែលយើងអាចញ៉ាំបាន?
តោះរាប់ជាមួយគ្នា ១ ២ ៣ ៤ ៥ ៦ ៧! មាន៧ផ្លែ។



# ຟ





ម៉ែនៅទីនេះ! គាត់ត្រឡប់មកពីធ្វើការវិញហើយ។ គាត់មានហាងលក់ចេកចៀនមួយ។
ថ្ងៃនេះ គ្រប់គ្នានឹងមកលេងពួកយើង ដូច្នេះគាត់បានយកចេកចៀនខ្លះៗមកផ្ទះ។
តើមានចេកចៀនចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥ ៦ ៧ ៨! យ៉េ! មាន៨ដុំ។





លោកយាយបានមកដល់ផ្ទះ! សួស្តីសុខា! តើចៅចូលចិត្តនំអន្សមមែនទេ?
លោកយាយបានទិញនំអន្សមផ្ញើចៅ។ យេ៎! អរគុណលោកយាយ។
តើមាននំអន្សមចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩! មាន៩នំ។

# ဋ



# ១០



ថ្ងៃនេះ គ្រួសាររបស់ខ្ញុំបានមកជួបជុំគ្នា។លោកយាយនិងលោកតា ម៉ាក់និងប៉ា
បងស្រីនិងបងប្រុស ខ្ញុំនិងប្អូនប្រុសពៅ ហើយបន្ទាប់មកគឺបងប្អូនជីដូនមួយ
ចំនួនពីរនាក់ទៀត។ តើទាំងអស់គ្នាមានចំនួនប៉ុន្មាននាក់?
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០! មានចំនួន ១០នាក់។
ពួកយើងញ៉ាំអាហារពេលល្ងាចជុំគ្នាយ៉ាងសប្បាយរីករាយ។

# ໑໐






# ផ្ទះរបស់សុខា

អ្នកនិពន្ធ៖TukTuk

អ្នកគំនូរ៖Kaho Yamda

គំនូរជីវចល

ធនធានបង្រៀន

អង្គការរុឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary